# នីតិវិធីនៃការលែងលះតាមផ្លូវច្បាប់សំរាប់ជនបរទេស

## 1. ការលែងលះដោយព្រមព្រៀង និងការលែងលះដោយជំនុំជំរះ

- យោងទៅតាមច្បាប់រដ្ឋប្បវេណី នៃសាធារណរដ្ឋកូរ៉េ នីតិវិធីនៃការលែងលះ មានពីរប្រភេទ គឺ ការលែងលះដោយការព្រមព្រៀង និងការលែងលះដោយការជំនុំជំរះ។
- ក្នុងករណីដែលគូស្វាមីភរិយាទាំងសងខាងយល់ព្រមក្នុងការលែងលះ និងសិទ្ធិក្នុងការចិញ្ចឹមកូន នោះគេអាចនឹងធ្វើការលែងលះដោយការព្រមព្រៀង។
- ក្នុងករណីដែលគូស្វាមីភរិយាទាំងសងខាង មិនយល់ព្រមក្នុងការលែងលះ នោះគេមិនអាចធ្វើការលែងលះដោយការព្រមព្រៀងទេ។ គូស្វាមីភរិយា ត្រូវធ្វើការដាក់ពាក្យលែងលះទៅតុលាការ រឺដាក់ស្នើសុំការផ្សះផ្សារពីតុលាការ។

## 2. ការដាក់ពាក្យបណ្តឹងលែងលះ

- ក្នុងករណីដែលមិនមានការយល់ព្រម រឺមានជំលោះទាក់ទងនឹងការលែងលះ ការបែងចែកទ្រព្យសម្បត្តិ សិទ្ធិក្នុងការចិញ្ចឹមកូន ការផ្គត់ផ្គង់កូន និងការទៅលេងកូន បុគ្គលត្រូវដាក់ពាក្យបណ្តឹងទៅតុលាការគ្រួសារដើម្បីដោះស្រាយជំលោះ។ នីតិវិធីដូចគ្នានេះដែរ នឹងអនុវត្តនៅពេលដែលបុគ្គលធ្វើការដាក់ពាក្យលែងលះ។
- នៅក្នុងបណ្តឹងលែងលះ បុគ្គលអាចទាមទារការលែងលះ ព្រមទាំងការបែងចែកទ្រព្យសម្បត្តិ។ ប្រសិនបើបុគ្គលមិនបានបញ្ជាក់បន្ថែមនោះទេ នោះតុលាការនឹងមិនធ្វើការកាត់ក្តីចំពោះការបែងចែកទ្រព្យសម្បត្តិឡើយ។
- សំណើនៃ 'ការដោះស្រាយការលែងលះ' គឺសំដៅទៅលើការសងជំងឺចិត្តចំពោះការខូចខាតផ្នែកផ្លូវចិត្ត ដែលបង្កឡើងដោយភាគីម្ខាងទៀតដែលជាមូលហេតុបង្ក អោយមានការបែកបាក់ក្នុងជីវិតអាពាហ៍ពិពាហ៍។
- សំណើនៃ 'ការបែងចែកទ្រព្យសម្បត្តិ' សំដៅទៅលើការបែងចែកទ្រព្យសម្បត្តិរបស់គូស្វាមីភរិយា ដែលទ្រព្យសម្បត្តិនោះ គឺជាទ្រព្យសម្បត្តិរួមបានមកពីការប្រឹងប្រែងរួមរបស់គូស្វាមីភរិយា ក្នុងជីវិតអាពាហ៍ពិពាហ៍។

- ប្រសិនបើគូស្វាមីភរិយា មានកូនមិនទាន់គ្រប់អាយុ នោះពួកគេនឹងត្រូវធ្វើការសំរេចចិត្តអំពី 'សិទ្ធិក្នុងការគ្រប់គ្រង និងការចិញ្ចឹមកូន', 'ការផ្គត់ផ្គង់កូន' និង 'ការទៅលេងកូន'។

### 3. មូលហេតុនៃការលែងលះតាមផ្លូវច្បាប់

យោងតាមមាត្រា 840 នៃច្បាប់រដ្ឋប្បវេណីរបស់សាធារណរដ្ឋកូរ៉េ បុគ្គលអាចដាក់ពាក្យបណ្តឹងលែងលះបាន នៅពេលដែលមានមូលហេតុណាមួយខាងក្រោម។

| |
|---|
| ច្បាប់រដ្ឋប្បវេណី មាត្រាទី 840 (មូលហេតុនៃការលែងលះតាមផ្លូវច្បាប់)<br>បុគ្គលអាចដាក់ពាក្យបណ្តឹងលែងលះ នៅពេលដែលមានមូលហេតុណាមួយខាងក្រោម។<br>1. នៅពេលដែលភាគីណាមួយធ្វើអាកប្បកិរិយាមិនគប្បីទៅលើភាគីមួយទៀត។<br>2. នៅពេលដែលភាគីណាមួយបោះបង់ភាគីណាមួយក្នុងរយៈពេលមួយយូរគួរសម។<br>3. នៅពេលដែលភាគីណាមួយ ត្រូវក្រុមគ្រួសារម្ខាងទៀតធ្វើសកម្មភាពមិនគប្បីធ្ងន់ធ្ងរដាក់។<br>4. នៅពេលដែលក្រុមគ្រួសារនៃភាគីណាមួយ ត្រូវបានភាគីម្ខាងទៀតធ្វើសកម្មភាពមិនគប្បីធ្ងន់ធ្ងរដាក់។<br>5. នៅពេលដែលជីវិតនៃភាគីណាមួយមិនច្បាស់លាស់ ក្នុងរយៈពេល 3 ឆ្នាំខាងមុខ។<br>6. នៅពេលដែលមិនមានមូលហេតុមូលដ្ឋានដើម្បីអោយបន្តជីវិតអាពាហ៍ពិពាហ៍បន្តទៅទៀត។ |

## 4. សង្ខេបនៃការដាក់ពាក្យបណ្ដឹង និងនីតិវិធីនៃការសំរបសំរួល



## 5. នីតិវិធីនៃការលែងលះដោយការជំនុំជំរះ

### A. ការបញ្ជូនច្បាប់ថតចំលងនៃពាក្យបណ្តឹង

- នៅពេលដែលដើមបណ្តឹងដាក់ពាក្យបណ្តឹងទាមទារលែងលះ តុលាការនឹងធ្វើការបញ្ជូនច្បាប់ថតចំលងនៃពាក្យបណ្តឹងទៅអោយចុងចំលើយ។ ក្នុងករណីដែលមិនមានអាស័យដ្ឋានរបស់ចុងចំលើយ នោះការជូនដំណឹងអំពីពាក្យបណ្តឹងអាចធ្វើឡើងបានតាមរយៈការផ្សព្វផ្សាយជាសាធារណៈ ទៅតាមលក្ខខណ្ឌនៃការផ្សព្វផ្សាយ នោះមានប្រសិទ្ធិភាព។

### B. សំណើសុំបញ្ជាការពារមុននឹងចេញសាលដីកា

- មុននឹងទទួលបានការសំរេចជាស្ថាពរទាក់ទងនឹងពាក្យបណ្តឹងលែងលះ រឺសំណើផ្សះផ្សារ បុគ្គលអាចធ្វើការស្នើសុំបញ្ជាការពារបានក្នុងករណីបន្ទាប់។
- តុលាការអាចនឹងអនុវត្តបញ្ជាការពារទៅតាមភាពជាក់ស្តែង និងសិទ្ធិរបស់ខ្លួន ទោះបីជាមិនមានសំណើពីបុគ្គលក៏ដោយ។
- បញ្ជាការពារនឹងអាចផ្តល់អោយក្នុងករណីដូចខាងក្រោម៖
  · នៅពេលដែលភាគីម្ខាង មិនអនុញ្ញាតអោយទៅរកភាគីម្ខាងទៀត។
  · នៅពេលដែលភាគីម្ខាង ត្រូវការទាមទារសំណងហិរញ្ញវត្ថុ
រឺការផ្គត់ផ្គង់ដល់កូនដែលមិនទាន់គ្រប់អាយុ។
  · នៅពេលដែលមានសំណើទៅលេងកូន។
- បណ្តឹងជំទាស់អាចដាក់ជូនជាថ្មីម្តងទៀត ក្នុងអំលុងពេល 7 ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងទាក់ទងនឹងការសំរេចនៃបញ្ជាការពារ។ ការសំរេចនឹងចូលជាធរមាន បន្ទាប់ពីបានធ្វើការសំរេចចុងក្រោយ។
- តុលាការគ្រួសារមានសិទ្ធិធ្វើការផាកពិន័យរហូតដល់ 10,000,000 វ៉ុន ចំពោះបុគ្គលណាដែលរំលោភលើបញ្ជារបស់តុលាការ។

### C. ការតវ៉ា

- នៅពេលដែលច្បាប់ថតចំលងនៃពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់ចុងចំលើយ ចៅក្រមនឹងធ្វើការកំណត់ និងធ្វើការជូនដំណឹងនូវកាលបរិច្ឆេទសំរាប់ធ្វើការតវ៉ា។ នៅក្នុងថ្ងៃធ្វើការតវ៉ា បុគ្គលពាក់ព័ន្ធទាំងអស់ត្រូវតែចូលរួម

លើកលែងតែស្ថិតក្នុងស្ថានភាពពិសេសដែលមិនអនុញ្ញាតអោយបុគ្គលមកចូលរួមបាន។
ប្រសិនបើបុគ្គលមិនបានចូលរួមទៅតាមការកោះហៅរបស់តុលាការដោយគ្មានមូលហេតុ នោះអាចនឹងត្រូវផាកពិន័យជាប្រាក់ចំនួនក្រោម 500,000 វ៉ុន។

- នៅក្នុងថ្ងៃតវ៉ា ភាគីទាំងពីរត្រូវធ្វើការការពារនូវការអះអាងរបស់ខ្លួន (ដូចជាមូលហេតុជាក់លាក់ដែលឈានទៅដល់ការលែងលះដោយជំនុំជំរះ) ដាក់បង្ហាញនូវឯកសារដែលពាក់ព័ន្ធ និងធ្វើការពិនិត្យមើលលើភស្តុតាងស៊ើបអង្កេត និងការសាកសួរសាក្សី។

- ខុសពីរឿងក្តីស៊ីវិល ដែលករណីលែងលះអាចសំរេចទៅតាមសិទ្ធិអំណាចរបស់បុគ្គលតែមួយ។ តុលាការគ្រួសារនឹងធ្វើការពិនិត្យទៅលើការពិតជាក់ស្តែងជាមូលដ្ឋាន ដើម្បីធ្វើការសំរេច។ សិទ្ធិបុគ្គលនឹងត្រូវបានប្រើប្រាស់ក្នុងការស៊ើបអង្កេត រឺការស៊ើបអង្កេតលើភស្តុតាង។ តុលាការមានសិទ្ធិសួរដេញដោលអ្នកតំណាងបុគ្គល និងអ្នកតំណាងផ្នែកច្បាប់គ្រប់ពេលវេលា។

## D. ការស៊ើបអង្កេតក្នុងគ្រួសារ

- តុលាការគ្រួសារអាចបញ្ជាអោយអ្នកស៊ើបអង្កេតក្នុងគ្រួសារ ធ្វើការស៊ើបអង្កេតក្នុងគ្រួសារ មុននឹង រឺក្នុងអំលុងពេលតវ៉ា។ ការស៊ើបអង្កេតក្នុងគ្រួសារអាចធ្វើទៅបានក្នុងអំលុងពេលនីតិវិធីនៃការផ្សះផ្សារ។
- អ្នកស៊ើបអង្កេតក្នុងគ្រួសារ នឹងធ្វើការស៊ើបអង្កេតក្នុងគ្រួសារទៅលើកត្តាផ្សេងៗ ដែលបណ្តាលអោយមានការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ក៏ដូចជាការអប់រំ និងប្រវត្តិការងារ លក្ខខណ្ឌនៃការរស់នៅ និងទ្រព្យសម្បត្តិ អត្តចរិត និងបរិយាកាសក្នុងគ្រួសារ ដែលពាក់ព័ន្ធនឹងបុគ្គល ដោយយោងទៅតាមផ្នែកចិត្តសាស្ត្រ សង្គមសាស្ត្រ សេដ្ឋកិច្ច គរុកោសល្យ និងចំណេះដឹងអាជីពផ្សេងទៀត។

- ខ្លឹមសារនៃការស៊ើបអង្កេតរួមមានដូចខាងក្រោមៈ
    - o ការស៊ើបអង្កេតអំពីការពិតៈ
      មូលហេតុនៃការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍
      ការវិវត្តនៃការបង្កើតទ្រព្យសម្បត្តិរួមគ្នា
      សិទ្ធិក្នុងការចិញ្ចឹមកូនរបស់ភាគីទាំងពីរជាដើម។
    - o វិធានការនៃការផ្សះផ្សារៈ
      ការផ្សះផ្សារដោយផ្ទាល់ពីអ្នកស៊ើបអង្កេតក្នុងគ្រួសារ
      ដើម្បីអោយទទួលការព្យាបាលផ្នែកផ្លូវចិត្ត ការព្យាបាលការញៀនថ្នាំ
      និងញៀនល្បែងជាដើម។

## E. ការផ្សះផ្សារ

- នៅក្នុងថ្ងៃដែលធ្វើការផ្សះផ្សារ ភាគីទាំងសងខាងត្រូវតែមានវត្តមាន។
  អាចនឹងមានការចូលរួមពីអ្នកតំណាងផ្នែកច្បាប់របស់ភាគីទាំងសងខាង។
- នៅក្នុងថ្ងៃដែលធ្វើការផ្សះផ្សារ ការផ្សះផ្សារអាចធ្វើទៅបាន
  ក្នុងករណីដែលភាគីទាំងសងខាងបានយល់ព្រមជាមួយនឹងសំណើរបស់តុលាការ
  រឺគណៈកម្មាការផ្សះផ្សារ។ នៅពេលដែលការផ្សះផ្សារបានសំរេច
  តុលាការនឹងរៀបចំ ព្រមទាំងធ្វើចេញនូវរបាយការណ៍ផ្សះផ្សារ
  រួមមានខ្លឹមសារនៃការផ្សះផ្សារ ដែលយល់ព្រមដោយភាគីទាំងសងខាង។
- ប្រសិនបើការផ្សះផ្សារ មិនបានសំរេចទេនោះ តុលាការអាចចេញបញ្ជាអោយ មាន
  "ការសំរេចចិត្តជំនួសការផ្សះផ្សារ (ការផ្សះផ្សារដោយការបញ្ជា)"។
  ប្រសិនបើភាគីទាំងសងខាងមិនបានដាក់ពាក្យតវ៉ាក្នុងអំលុងពេល 14 ថ្ងៃ
  បន្ទាប់ពីការចេញ "ការសំរេចចិត្តជំនួសការផ្សះផ្សារ" ទេនោះ នឹងសំរេចថា
  ការសំរេច នោះ គឺជាការសំរេចចុងក្រោយ។
- របាយការណ៍ផ្សះផ្សារ រឺការសំរេចចុងក្រោយជំនួសការផ្សះផ្សារ
  មានសុពលភាពស្មើគ្នា នឹងការសំរេចចុងក្រោយដែរ។ ហេតុដូចនេះ
  នៅពេលមានការផ្សះផ្សារសំរេច នោះបុគ្គលមិនអាចធ្វើការតវ៉ាបានទេ។

## F. បញ្ជាផ្សះផ្សារ

- តុលាការដែលទទួលបន្ទុកក្នុងរឿងក្តីអាចនឹងចេញបញ្ហាផ្សះផ្សារទៅតាមសិទ្ធិរបស់ខ្លួន ក្នុងអំលុងពេលកាត់ក្តី ដើម្បីទទួលបាននូវដំណោះស្រាយដ៏ល្អមួយ។
- ប្រសិនបើបុគ្គលមិនបានដាក់ពាក្យតវ៉ា ក្នុងអំលុងពេល 2 សប្តាហ៍បន្ទាប់ពីទទួលបានបញ្ហាផ្សះផ្សារ នោះបញ្ហាផ្សះផ្សារ នឹងក្លាយជាការសំរេចចុងក្រោយ ដែលឈានទៅដល់ការបញ្ចប់រឿងក្តី។
- នៅពេលដែលបញ្ហាផ្សះផ្សារត្រូវបានសំរេច នោះបុគ្គលមិនអាចធ្វើការតវ៉ាបានទេ។

## G. ការបញ្ចប់រឿងក្តី

- តុលាការនឹងប្រកាសសាលដីកា នៅក្នុងសវនាការដើម្បីបបញ្ចប់រឿងក្តី។

## H. នីតិវិធីនៃបណ្តឹងឧទ្ធរណ៍

កាត់ក្តីលើកទីមួយ → កាត់ក្តីលើកទីពីរ → កាត់ក្តីលើកទីបី

បណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍

- បុគ្គលអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន ក្នុងអំលុងពេល 2 សប្តាហ៍ បន្ទាប់ពីទទួលបានការសំរេចក្នុងការកាត់ក្តីលើកទីមួយ។ នៅក្នុងពេលធ្វើការដាក់ពាក្យ បណ្តឹងឧទ្ធរណ៍ ត្រូវដាក់ទៅតុលាការ ដែលធ្វើការសំរេចចុងក្រោយ។
- បន្ទាប់ការចេញការសំរេចពីតុលាការឧទ្ធរណ៍ បុគ្គលអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ម្តងទៀតទៅតុលាការកំពូលក្នុងអំលុង 2 សប្តាហ៍បន្ទាប់ពីការសំរេច។ នៅពេលដែលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅតុលាការកំពូល ត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់តុលាការកំពូល។
- នៅពេលដែលបុគ្គល មិនបានធ្វើការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទាន់ពេលវេលាបន្ទាប់ពីការសំរេចនៅក្នុងការកាត់ក្តីលើកទីមួយ ហើយបណ្តឹងឧទ្ធរណ៍ត្រូវបានច្រានចោលដោយសារតែមិនមានការដាក់ពាក្យបណ្តឹ

ងឧទ្ធរណ៍បន្តទៅទៀត
រឺនៅពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅក្នុងតុលាការជាន់ខ្ពស់
ហើយត្រូវបានច្រានចោល នោះការសំរេចនៅក្នុងការកាត់ក្តីលើកទីមួយ
គឺជាការសំរេចចុង ក្រោយ។

- ប្រសិនបើការកាត់ក្តីត្រូវបានធ្វើឡើងដោយចំហរ ចុងចោទអាចធ្វើការដាក់ពាក្យបណ្តឹងឧទ្ធរណ៍
ដោយបញ្ជាក់ពីមូលហេតុដែលខ្លួនដាក់ពាក្យបណ្តឹងឧទ្ធរណ៍មិនបានទាន់ពេលវេលា នៅក្នុងករណីដែលចុងចោទ ទើបតែដឹងថា ការសំរេចចិត្តនៃការលែងលះត្រូវបានសំរេចបន្ទាប់ពីចេញសាលដីកា។
- នៅពេលដែលមានកំហុសបន្តិចបន្តួចដែលទាមទារអោយមានការកែតំរូវនៅក្នុងខ្លឹមសារនៃសាលដីកា (ដូចជាសុវត្ថិភាពសង្គម រឺទីតាំងកំណត់ហេតុ) ត្រូវបានរកឃើញ នោះបុគ្គលអាចស្នើអោយមានការវាយតំលៃម្តងទៀតនៅក្នុងតុលាការដែលពាក់ព័ន្ធ។

## I. នីតិវិធីបន្ទាប់ការចេញសាលដីកា រឺការសំរេចផ្សេងៗ

- ដើម្បីរៀបចំទំនាក់ទំនងនៅក្នុងប័ណ្ណបញ្ជាក់ទំនាក់ទំនងគ្រួសារ
បន្ទាប់ពីការបញ្ចប់រឿងក្តី ដោយការសំរេច រឺដោយការសំរបសំរួល
បុគ្គលត្រូវធ្វើការចុះបញ្ជីលិខិត សំរេច (រឺបញ្ជាផ្សះផ្សារ) ផ្ញើលិខិត
និងលិខិតបញ្ជាក់ទៅកាន់ការិយាល័យរដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងអំលុងពេល 1 ខែ បន្ទាប់ពីការសំរេចចុងក្រោយ រឺចុះបញ្ជីរបាយការណ៍ផ្សះផ្សារ
ជាមួយនឹងឯកសារទាំងឡាយដែលបានលើកឡើងខាងលើជាមួយនឹងការិយាល័យរដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងអំលុងពេល 1 ខែ បន្ទាប់ពីមានការផ្សះផ្សារ។
- លិខិតបញ្ជាក់ចុងក្រោយ និងការចេញលិខិតទាំងឡាយ
នឹងផ្តល់អោយដោយតុលាការដែលធ្វើការកាត់ក្តី។

## 6. ការធ្វើសញ្ជាតូបនីយកម្ម និងការផ្តល់សិទ្ធិក្នុងការរស់នៅ

- ការធ្វើសញ្ជាតូបនីយកម្ម និងការផ្តល់សិទ្ធិក្នុងការរស់នៅ មិនមែនជាអាជ្ញាសិទ្ធិរបស់តុលាការទេ។ វាស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងយុត្តិធម៌។
- សំរាប់ព័ត៌មានបន្ថែមទាក់ទងនឹងការធ្វើសញ្ជាតូបនីយកម្ម និងការផ្តល់សិទ្ធិក្នុងការរស់នៅ សូមទៅកាន់គេហទំព័រនៃការិយាល័យអន្តោប្រវេសន៍កូរ៉េតាមរយៈ: www.immigration.go.kr។

7. សេវាកម្មបកប្រែផ្ទាល់មាត់សំរាប់ជនបរទេស

A. ជំនួយក្នុងការបកប្រែផ្ទាល់មាត់

- តុលាការគ្រួសារ នឹងផ្តល់ជំនួយបកប្រែផ្នែកច្បាប់ដល់ជនបរទេសដែលមានកំរិតភាសាកូរ៉េទាប និងការផ្តល់ជំនួយផ្នែកច្បាប់សំរាប់ការបង់ថ្លៃសេវាកម្មបកប្រែផ្ទាល់មាត់។ ប្រសិនបើអ្នកមិនមានអ្នកជំនួយបកប្រែភាសាមកជាមួយទេនោះ អ្នកត្រូវដាក់ពាក្យស្នើសុំការចាត់តាំងអ្នកបកប្រែភាសាផ្ទាល់មាត់ពីតុលាការ។

B. ជំនួយផ្នែកច្បាប់

- ជំនួយផ្នែកច្បាប់ គឺជាប្រព័ន្ធដែលរដ្ឋាភិបាលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលដែលមិនមានលទ្ធភាពបង់ថ្លៃសោហ៊ុយសំរាប់សេវាផ្នែកច្បាប់។ នៅពេលដែលម្នាក់ត្រូវបានជ្រើសរើសជាអ្នកទទួលបានជំនួយផ្នែកច្បាប់ហើយនោះ ការចំណាយផ្នែកច្បាប់មួយផ្នែក នឹងត្រូវទទួលបន្ទុកដោយរដ្ឋាភិបាល។

- ការចំណាយផ្នែកច្បាប់រួមមាន ថ្លៃតែម ថ្លៃបញ្ជូនឯកសារ ថ្លៃបកប្រែភាសា ថ្លៃវាយតំលៃ និងថ្លៃមេធាវី។

C. ប្រព័ន្ធចាត់តាំងមេធាវីតំណាងសំរាប់ជនបរទេសក្នុងការផ្តល់ជំនួយផ្នែកច្បាប់

- តុលាការគ្រួសារសេអ៊ូល អនុវត្តប្រព័ន្ធចាត់តាំងមេធាវីតំណាងសំរាប់ជនបរទេសក្នុងការផ្តល់ជំនួយផ្នែកច្បាប់ ដោយសហការជាមួយនឹងគណៈមេធាវីក្រុងសេអ៊ូល។ នៅពេលដែលជនបរទេសសាកសួរព័ត៌មានអំពីជំនួយផ្នែកច្បាប់ ខាងតុលាការនឹងធ្វើការណែនាំ "ប្រព័ន្ធចាត់តាំងមេធាវីតំណាងសំរាប់ជនបរទេសក្នុងការផ្តល់ជំនួយផ្នែកច្បាប់" ដល់អ្នកនៅពេលមានបញ្ហាណាមួយកើតឡើងក្នុងការចាត់តាំងមេធាវីតំណាង បន្ទាប់ពីអ្នកបានដាក់ពាក្យស្នើសុំ ហើយសំណើជំនួយផ្នែកច្បាប់របស់អ្នកត្រូវបានអនុញ្ញាត។

- ជនបរទេស នឹងត្រូវបានផ្តល់អោយនូវសេវាកម្មផ្នែកច្បាប់ពេញលេញ ចាប់ផ្តើមពីពេលប្រឹក្សារហូតដល់ជំនួយផ្នែកច្បាប់ ដោយអនុវត្តប្រព័ន្ធចាត់តាំងមេធាវីតំណាងសំរាប់ជនបរទេសក្នុងការផ្តល់ជំនួយផ្នែកច្បាប់។